NSW GOVERNMENT

**Student behaviour**
**Parent/carer factsheet**

# អាកប្បកិរិយារបស់សិស្ស

## ខិត្តប័ណ្ណព័ត៌មានសម្រាប់ឪពុកម្តាយ/អ្នកថែទាំ

### អាកប្បកិរិយា

យើងចង់ធានាថាសាលារៀនមានសុវត្ថិភាព និងរីករាយសម្រាប់កូនរបស់អ្នក។ ការគាំទ្រអាកប្បកិរិយារបស់សិស្សគឺមានសារៈសំខាន់ដើម្បីលើកកម្ពស់ ការចូលរួម និងលើកកំពស់ការអនុវត្ត និងសុខុមាលភាពរបស់សិស្ស។ សាលារៀនមានគោលបំណងផ្តល់នូវបរិយាកាសរៀនសូត្ររួមបញ្ចូល ដែលសហការ គាំទ្រ និងជាប់ទាក់ទងគ្នា។ ធម្មនុញ្ញសហគមន៍សាលារៀន គូសបញ្ជាក់ពីរូបសណ្ឋាននេះសម្រាប់ឪពុកម្តាយ អ្នកថែទាំ អ្នកអប់រំ និងបុគ្គលិកសាលា។

### យុទ្ធសាស្រ្តអាកប្បកិរិយារបស់សិស្ស

យុទ្ធសាស្រ្តអាកប្បកិរិយារបស់សិស្ស (Student Behaviour Strategy) របស់យើង ជួយសាងសង់ប្រព័ន្ធអប់រំរួមបញ្ចូល ដែលសិស្សគ្រប់រូបត្រូវបានគេស្គាល់ ឱ្យតម្លៃ និងយកចិត្តទុកដាក់ ហើយសិស្សទាំងអស់អាចរៀនអស់ពីសមត្ថភាពរបស់ពួកគេ។ យើងដឹងថា សិស្សដែលមានអារម្មណ៍ថាត្រូវបានគាំទ្រ និងមានសុវត្ថិភាព ទំនងជាបានតភ្ជាប់ជាមួយសាលារៀនកាន់តែច្រើន និងជាអ្នកចូលរួមសកម្មក្នុងការរៀនសូត្ររបស់ពួកគេ។

បរិយាកាសរៀនសូត្រប្រកបដោយវិជ្ជមាន និងគួរឱ្យគោរព លើកកម្ពស់សុខុមាលភាព ការទាក់ទិន និងការកែលម្អសមិទ្ធិផលសិក្សា។ យុទ្ធសាស្រ្តនេះគាំទ្រវិធីសាស្រ្តដែលបង្ការ ប្រកបដោយវិជ្ជមាន ដែលផ្តោតលើសិស្ស សាលារៀន-គ្រួសារ-សហគមន៍ ហើយដែលភាពស្ថិតស្ថេរគឺជាគន្លឹះ។ តម្រូវការរបស់សិស្សទាំងអស់នឹងត្រូវបានបំពេញដោយសម្ព័ន្ធថែទាំបន្តគ្នា (Care Continuum)។

### ក្រមអាកប្បកិរិយាសម្រាប់សិស្ស

ក្រមអាកប្បកិរិយាសម្រាប់សិស្ស (Behaviour Code for Students) បង្ហាញពីអាកប្បកិរិយាដែលត្រូវបាន រំពឹងទុកនៅក្នុងសាលារៀនរដ្ឋក្នុងរដ្ឋ NSW ទាំងអស់។ សាលារៀនរបស់កូនអ្នក ក៏នឹងបង្កើតការរំពឹងទុកខាងអាកប្បកិរិយាដែលនឹងត្រូវបានរំពឹងទុកនៅក្នុងសាលារៀនរបស់ពួកគេផងដែរ។ បុគ្គលិកនៅសាលារៀនរបស់កូនអ្នកនឹងបង្រៀន ហើយទទួលស្គាល់អាកប្បកិរិយាដែលរំពឹងទុកនេះ។

### អាកប្បកិរិយាគួរឱ្យព្រួយបារម្ភ

កុមារ និងក្មេងវ័យជំទង់អាចបង្ហាញអាកប្បកិរិយាប្រឈមនៅពេលខ្លះ ដែលជាផ្នែកធម្មតានៃការធំលូតលាស់។ កូនរបស់អ្នកអាចរងផលប៉ះពាល់ដោយអាកប្បកិរិយារបស់អ្នកដទៃ ឬប៉ះពាល់ដល់អ្នកដទៃដោយអាកប្បកិរិយារបស់ពួកគេ។ ព័ត៌មានបន្ថែមអាចរកបាននៅលើគេហទំព័រ អំពីអ្វីដែលត្រូវធ្វើ ប្រសិនបើកូនរបស់អ្នកបានប្រាប់អ្នក អំពីបញ្ហាអាកប្បកិរិយានានានៅសាលារៀន។

### ព័ត៌មានបន្ថែម

ប្រសិនបើអ្នកចង់ដឹងបន្ថែមអំពីការគាំទ្រផ្នែកអាកប្បកិរិយា ឬមានកង្វល់ណាមួយអំពីអាកប្បកិរិយារបស់កូនអ្នក សូមទាក់ទងមកសាលារៀន។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកមានបំណងចង់ទាក់ទងមកសាលារៀន ហើយត្រូវការជំនួយផ្នែកភាសាអង់គ្លេស សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ តាមលេខ 131 450 ប្រាប់ពួកគេពីភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យការីទូរសព្ទ ទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកនៅក្នុងការសន្ទនារបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។